ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៤៦២ ...សហវ.ប្រក

# ប្រកាស

## ស្ដីពី

## នីតិវិធីអនុវត្តឋវិកាបដិភាគសម្រាប់ដំណើរការ និងប្រតិបត្តិការសកម្មភាព របស់គម្រោងលើកកម្ពស់គុណភាព និងសមធមិសុខាភិបាល

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងដាក់ឱ្យអនុវត្តអង្គភាពថវិកា
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២ ស្ដីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមបច្ចុប្បន្នកម្ម សម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍
- យោងប្រកាសលេខ ៧២០ សហវ.ប្រក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៣ ស្ដីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្ដីពីការរៀបចំ និងដាក់ឱ្យអនុវត្តសាកល្បងអង្គភាពថវិកា
- យោងប្រកាសលេខ ៨៥៦ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្ដីពីការរៀបចំ និងចាប់ផ្ដើមដាក់ឱ្យអនុវត្តអង្គភាពថវិកា
- កិច្ចព្រមព្រៀងឥណទានសម្បទានលេខ 5813-KH និងហិរញ្ញប្បទានឥតសំណងលេខ TFOA3114 សម្រាប់គម្រោងលើកកម្ពស់គុណភាព និងសមធមិសុខាភិបាល រវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារពិភពលោក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ ២០១៦។
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St. 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CABOMDIA.
ទូរសព្ទ៍ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ ១.-**

ថវិកាសម្រាប់ដំណើរការ និងប្រតិបត្តិការសកម្មភាពរបស់គម្រោងលើកកម្ពស់គុណភាព និងសមធមិសុខាភិបាល ត្រូវគ្រោងក្នុងអនុគណនីលេខ ៦២០២១ (ជំនួយដល់ប្រជាជនសំរាកពេទ្យ និងចំណាយដំណើរការរបស់មណ្ឌលថែទាំសុខភាព) នៃកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងសុខាភិបាល ។

**ប្រការ ២.-**

វិធាននៃការអនុវត្តចំណាយថវិកាសម្រាប់ដំណើរការ និងប្រតិបត្តិការសកម្មភាពរបស់គម្រោងលើកកម្ពស់គុណភាព និងសមធមិសុខាភិបាល ត្រូវអនុវត្តតាមនីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុគម្រោង ដោយអនុលោមតាមអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមបច្ចុប្បន្នកម្ម សម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍។

**ប្រការ ៣.-**

ថវិកាសម្រាប់ដំណើរការ និងប្រតិបត្តិការសកម្មភាពរបស់គម្រោងលើកកម្ពស់គុណភាព និងសមធមិសុខាភិបាល ត្រូវបើកផ្តល់សាច់ប្រាក់ប្រចាំត្រីមាស ដោយអាណត្តិបើកប្រាក់។

**ប្រការ ៤.-**

អនុញ្ញាតឱ្យបន្តរក្សាសមតុល្យសាច់ប្រាក់នៅក្នុងគណនីថវិកាបដិភាគនៃគម្រោងលើកកម្ពស់គុណភាព និងសមធមិសុខាភិបាល នៅចុងឆ្នាំសារពើពន្ធ ដើម្បីប្រើជាបុរេប្រទានសម្រាប់ឆ្នាំបន្ទាប់ និងត្រូវអនុវត្តនីតិវិធីបំពេញឡើងវិញ នៅពេលដែលឥណទានថវិកាឆ្នាំថ្មីត្រូវបានដំណើរការ។

**ប្រការ ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៦.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យសម្តេច ឯកឧត្តមលោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ